ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣*៤៤

លេខៈ ១០១

ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤ **នាមនាមប្រជារាស្ត្រខ្មែរ**

**សាលដីកា** **តុលាការកំពូល**

លេខៈ ១៩១ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៤

ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម** | **ប៉ុណ្ណ** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ប្រាក់ | គឹមសាន | ជាចៅក្រមរបាយការណ៍ |
| ៣-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៤-លោក | គង់ | ភីរុន | ជាចៅក្រម |
| ៥-លោក | យស់ | សូខឿន | ជាចៅក្រម |

ក្រឡាបញ្ជី

លោក **ម៉ៅ សុខណ្ណ**

តំណាងមហាអយ្យការ

លោក **សាយ សារី** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ១១៦"ច" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧៤៥ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ឡាច ទេវរា** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរមេផ្ទះ ទីលំនៅផ្ទះលេខ០១C ផ្លូវលេខ៣៣៦ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវី លោក កែវ យ៉ា ។

ចុងចម្លើយលោក **ព្រះរាជអាជ្ញារង អមតុលាការខេត្តកណ្តាល** (ជាចុងបណ្តឹងសាទុក្ខ)។

<u>**កម្មវត្ថុចណ្តឹង**</u> : ប្តឹងពីការប្រកាសលក់ឡាយឡុងរបស់ព្រះរាជអាជ្ញារង. អមតុលាការខេត្តកណ្តាល .

បានឃើញបណ្តឹងសាទុក្ខលេខ ៣២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៤ របស់លោកមេធាវី កែវ យ៉ា ការពារឱ្យដើមចោទ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១១៦"ច" ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១០១ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងអ្នកស្រីឡាច ខេមរាប្តឹងជំទាស់នឹងការប្រកាសលក់ឡាយឡុងរបស់ព្រះរាជអាជ្ញារងខេត្តកណ្តាលលេខ ៤៦៥ ប្រកលឡ ០៣ ចុះថ្ងៃទី២៦-៨-២០០៣ ដោយសំអាងហេតុថា ព្រះរាជអាជ្ញាខេត្តកណ្តាល បានប្រកាសលក់ឡាយឡុងម្តងរួចមកហើយ ដីទំហំ ១៤.០០៩ម៉ែត្រការេ ដែលស្ថិតជាប់ផ្លូវជាតិលេខ១ ត្រង់ចំណុចដើមពោធិ ភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

បានឃើញសេចក្តីប្រកាសលក់ឡាយឡុង លេខ ៤៦៥ ប្រ.ក.ល.ឡ០៣របស់អយ្យការអមតុលាការខេត្តកណ្តាល ដែលមានខ្លឹមសារដូចតទៅ :

យើងព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាល ចេញសេចក្តីប្រកាសលក់ឡាយឡុងជាថ្មី :

-ដីមួយកន្លែងមានទំហំ ១.៤០០៩ម$^2$ លក់តំលៃក្នុងមួយម៉ែត្រក្រឡា១៣ ដុល្លា (ដប់បីដុល្លាអាមេរិក) សរុប=១៣ x ១៤០០៩ ម$^2$ =១៨២.១១៧ដុល្លារអាមេរិក ។ ទីតាំងដីស្ថិតនៅជាប់ផ្លូវជាតិលេខ១ ត្រង់ចំណុចដើមពោធិ៍ ភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

-អចលនៈវត្ថុខាងលើនេះ ប្រកាសទទួលពាក្យដេញថ្លៃចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ អ្នកដាក់ពាក្យត្រូវបង់ប្រាក់កក់មុន ៥ភាគរយ នៃតំលៃដីខាងលើ ។

-អតិថិជនដែលត្រូវការដេញថ្លៃ សូមទំនាក់ទំនងនៅការិយាល័យអយ្យការអមតុលាការខេត្តកណ្តាល រៀងរាល់ម៉ោងធ្វើការ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០០២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះឡាច ខេមរា ប្តឹងមិនសុខចិត្តនឹងសេចក្តីប្រកាសលក់ឡាយឡុងលេខ៤៦៥ប្រ.ក.ល.ឡ០៣ ចុះថ្ងៃទី២៦ខែសីហា ឆ្នាំ២០០៣ របស់លោកព្រះរាជអាជ្ញារង អមតុលាការខេត្តកណ្តាល ត្រង់ចំណុច នៃសេចក្តីប្រកាសលក់ឡាយឡុងជាថ្មីទាំងស្រុង ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១១៦"ច" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦-៩-២០០៣ របស់អ្នកស្រីឡាច ខេមរា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទុកជាមោឃៈសេចក្តីសំរេចលក់ឡាយឡុង ចុះថ្ងៃទី៣១-៣-២០០៣ របស់លោកព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល ។

៣-តំកល់សេចក្តីប្រកាសលក់ឡាយឡុងលេខ ៤៦៥ប្រក.ល.ឡ០៣ ចុះថ្ងៃទី២៦-៨-២០០៣ របស់លោកព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាល ទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ៥.០០០រៀល និងលើអាជ្ញាធរតុលាការចំនួន ៥.០០០រៀល ។

៥-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងឧទ្ធរណ៍ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៤ របស់លោកមេធាវី កែវ យ៉ា ការពារឱ្យដើមចោទ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១១៦"ច" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០០៤ របស់ឈ្មោះឡាច ខេមរា ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១១៦"ច"ចុះថ្ងៃទី២៣-១២-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះផ្ទុយនឹងគតិច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះឡាច ខេមរា នាពេលសវនាការថា : ខ្លួនសុំបដិសេធការប្រកាសលក់ឡាយឡុងរបស់ព្រះរាជអាជ្ញារងខេត្តកណ្តាល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែវ យ៉ា ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា : កូនក្តីខ្លួនឈ្នះក្តីនៅតុលាការកំពូល ដោយតុលាការសំរេចឱ្យឈ្មោះស៊ឹម ស៊ុយតាំង សងប្រាក់ឱ្យកូនក្តីខ្លួន ។ កូនក្តីខ្លួនបានដាក់ពាក្យសុំអនុវត្តន៍សាលដីកា ហើយលោកហ៊ី សោភា បានប្រគល់ឱ្យលោកឆេង ផាត់ អនុវត្តន៍ ដោយបានធ្វើការរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង ។ ដីកាគឺសំរេចឱ្យព្រះរាជអាជ្ញាអនុវត្តន៍សាលដីកា មិនមែនឱ្យព្រះរាជអាជ្ញារងអនុវត្តន៍ទេ ហើយព្រះរាជអាជ្ញា ក៏មិនបានប្រគល់សិទ្ធិឱ្យព្រះរាជអាជ្ញារងដែរ ។

<u>សំណូមពរ</u> : -សុំបដិសេធការប្រកាសលក់ឡាយឡុងរបស់លោកព្រះរាជអាជ្ញារងហួតវុទ្ធី។

-សុំទទួលស្គាល់ការលក់ឡាយឡុងរបស់លោកព្រះរាជអាជ្ញាឆេង ផាត់ ។

-សុំបន្ថែមប្រាក់ឱ្យគ្រប់១៨២.១១៧ដុល្លារអាមេរិក ទៅតាមសេចក្តីប្រកាសលក់ឡាយឡុង ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ៣២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ២០០៤ របស់លោកកែវ យ៉ា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : ការដែលព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាលសំរេចប្រកាសលក់ឡាយឡុងតាមសេចក្តីប្រកាសលក់ឡាយឡុងលេខ៤៦៥ ប្រ.ក.ល.ឡ ចុះថ្ងៃទី២៦-៨-២០០៣ ហើយដែលសាលាឧទ្ធរណ៍សំរេចតម្កល់ទុកជាបានការនោះ គឺជាការភ័ន្តច្រឡំពីព្រោះថា :

+ ពុំមានភស្តុតាងណាមួយបញ្ជាក់ថា លោកព្រះរាជអាជ្ញារង បានទទួលការចាត់តាំងពីព្រះរាជអាជ្ញាឱ្យអនុវត្តសាលក្រមលេខ ០៥"ព" លេខ០៦"ព" លេខ ០៧"ព" លេខ០៨"ព" និងលេខ០៩"ព" របស់តុលាការខេត្តកណ្តាលឡើយ ដែលជាការរំលោភទៅលើគោលការណ៍ច្បាប់ជាមូលដ្ឋានដែលថា អយ្យការមានលក្ខណៈពុំអាចលែងចែកបានឡើយ មានន័យថា ព្រះរាជអាជ្ញារងបំពេញការងារតាមការបញ្ជាណែនាំពីព្រះរាជអាជ្ញា តាមមាត្រា៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

+សេចក្តីប្រកាសលក់ឡាយឡុងនេះធ្វើឡើងដោយយោងទៅលើលិខិតលេខ៣៧២ រ.ប.២០០៣ ចុះថ្ងៃទី០១-៧-២០០៣ របស់អយ្យការខេត្តកណ្តាល ហើយលិខិតនេះទៀតសោត ក៏ពុំមានចំណារទទួលដឹងឮពីព្រះរាជអាជ្ញាដែរ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១១៦"ច"ចុះថ្ងៃទី២៣-១២-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ

១-ទទួលបណ្តឹងសាទុក្ខលេខ ៣២ ចុះថ្ងៃទី២៦-០១-២០០៤ របស់អ្នកស្រីឡាច ខេមរា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១១៦"ច"ចុះថ្ងៃទី២៣-១២-២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១០១ចុះថ្ងៃទី២០-០២-២០០៤ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រំលងអ្នកប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលព្រះរាជអាជ្ញារង បានបង់គឺ:

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្គ៊ិងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ .

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៤ ។